# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបនាយកប្រតិបត្តិនៃការិយាល័យទឹកស្អាត និងទឹកក្រខ្វក់នៃទីក្រុង **Kitakyushu** ជប៉ុន




នៅរសៀលថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **ISAYAMA Osamu** នាយកប្រតិបត្តិនៃការិយាល័យទឹកស្អាត និងទឹកក្រខ្វក់ នៃទីក្រុង **Kitakyushu** ជប៉ុន ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។




ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ល្អរវាង កម្ពុជា និងទីក្រុង **Kitakyushu** ជប៉ុន រយៈពេលជាង១០ ឆ្នាំកន្លងទៅនេះ និងថ្លែងអំណរគុណចំពោះជំនួយបច្ចេកទេស

ជំនួយថវិកា និងការជួយបណ្តុះបណ្តាលធនធានមនុស្ស របស់ទីក្រុង **Kitakyushu** ដល់សិក្ខាកាមកម្ពុជាលើជំនាញទឹកស្អាត។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបន្តថា៖ការរីកចម្រើនលើវិស័យទឹកស្អាតនៅកម្ពុជា ពិតជាមិនអាចខ្វះបានពីការរួមចំណែកដ៏សំខាន់ពីប្រទេសជប៉ុនតាមរយៈអង្គការ JICA ។ ជាក់ស្តែង ដូចជារដ្ឋាករទឹកស្វយ័តទីក្រុងភ្នំពេញ បានទទួលពានរង្វាន់ជាបន្តបន្ទាប់ពីស្ថាប័នវាយតម្លៃអន្តរជាតិជាច្រើន ។ ទោះជាយ៉ាងណា ឯកឧត្តម ទេសរដ្ឋមន្ត្រី បានលើកឡើងពីការលំបាកមួយចំនួន ជាពិសេសគឺតម្លៃប្រើប្រាស់ទឹក ដែលមានភាពខុសៗគ្នាពីតំបន់មួយទៅតំបន់មួយ ពីព្រោះការវិនិយោគរបស់វិស័យឯកជន គឺគេគិតពីផលចំណេញជាចំបង ។ ទាក់ទងបញ្ហានេះ ឯកឧត្តម ទេសរដ្ឋ មន្ត្រី បានស្នើឱ្យទីក្រុង **Kitakyushu** ជប៉ុន ពិនិត្យលទ្ធភាពជួយរដ្ឋាករទឹកសាធារណៈកម្ពុជា ដើម្បីជួយពង្រីកវិសាលភាព និងសមត្ថភាពផ្នែកផ្គត់ផ្គង់ទឹក ធ្វើយ៉ាងណាឱ្យតម្លៃប្រើប្រាស់ទឹកមានលក្ខណៈសមរម្យ ស្របនិងជីវភាពរបស់ប្រជាពលរដ្ឋ។



ជាមួយនិងការកោតសរសើរ ពីបទពិសោធន៍និងជំនាញបច្ចេកទេសខ្ពស់លើវិស័យផលិតទឹកស្អាតរបស់ទីក្រុង **Kitakyushu** ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យការិយាល័យ ទឹកស្អាត និងទឹកក្រខ្វក់ នៃទីក្រុង **Kitakyushu** ជប៉ុន ពិនិត្យលទ្ធភាពជួយវិស័យទឹកស្អាត នៅតំបន់មាត់សមុទ្រកម្ពុជា ដែលមានការខ្វះទឹកសាបប្រើប្រាស់ និងនៅតំបន់ខេត្តសៀមរាប ។ ជាពិសេសខេត្តសៀមរាប ដែលជាខេត្តទេសចរណ៍ដ៏មានសក្តានុពល ការផ្គត់ផ្គង់ទឹកស្អាតមានមិនដល់៣០%ផង ហើយទីតាំងអាជីវកម្ម និងសេវាកម្ម ធំៗ គឺបានមកពីការបូមទឹកក្រោមដី ដែលនឹងអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ ដល់ប្រាសាទនានានៅតំបន់អង្គរវត្ត ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានថ្លែងអំណរគុណ ចំពោះអំណោយរបស់តំណាងទីក្រុង **Kitakyushu** នូវរថយន្តចល័តផលិតទឹកស្អាតមួយគ្រឿងដល់ខេត្តកែប ដែលមានលទ្ធភាពចល័តជួយផ្គត់ផ្គង់ទឹកស្អាត នៅតំបន់ដែលមានការខ្វះខាតទឹកផ្សេងៗ។







លោក **ISAYAMA Osamu** នាយកប្រតិបត្តិនៃការិយាល័យទឹកស្អាត និងទឹកក្រខ្វក់ នៃទីក្រុង **Kitakyushu** ជប៉ុន បានបញ្ជាក់ថាៈការចាប់ផ្តើមទំនាក់ទំនងតាំងពីឆ្នាំ១៩៩៩ មក រវាងកម្ពុជា និងទីក្រុង **Kitakyushu** ជប៉ុន ដៃគូទាំងពីរបានសម្រេចនូវគម្រោងអភិវឌ្ឍន៍វិស័យទឹកស្អាតជាច្រើន ហើយការមកទស្សនៈកិច្ច នាឱកាសនេះ ក៏ដើម្បី បញ្ចប់គម្រោងទឹកស្អាតមួយ ដែលនឹងប្រារព្ធធ្វើក្នុងសិក្ខាសាលា នាខេត្តសៀមរាប នៅថ្ងៃទី២៤ ខែ កក្កដា ខាងមុខនេះ ផងដែរ ។ ក្នុងនោះ គម្រោងចំនួនពីរ ដែលទីក្រុង **Kitakyushu** និងក្រសួងសុខាភិបាល ជប៉ុន បានចុះហត្ថលេខាជាមួយ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កម្ពុជា ស្តីពីការអភិវឌ្ឍន៍វិស័យទឹកស្អាតដោយសុវត្ថិភាព និងកិច្ចព្រមព្រៀងការ

អភិវឌ្ឍន៍វិស័យទឹកស្អាត នៅទីប្រជុំជន កាលពីឆ្នាំ២០១១ ភាគីជប៉ុន នៅតែសហការបន្តអនុវត្តកិច្ចព្រមព្រៀងនេះ ឱ្យបានចប់ជាស្ថាពរ ។

លោក **ISAYAMA Osamu** បាននំរលឹកថា: ចាប់ពីឆ្នាំ១៩៩៩ ទីក្រុង **Kitakyushu** បានបញ្ជូន ជំនាញការ និងអ្នកបច្ចេកទេសមកកម្ពុជា ប្រមាណចំនួន១០០នាក់ ដើម្បី ធ្វើការងារ ទាក់ទងផ្នែកគ្រប់គ្រងអាជីវកម្ម អភិវឌ្ឍន៍ស្ថាប័ន និងការផ្ទេរបច្ចេកវិទ្យាជាដើម ។ ក្នុងនោះក៏បានទទួលសិក្ខាកាមពីកម្ពុជាប្រមាណ៦០នាក់ផងដែរ ។

លោក **ISAYAMA Osamu** បានចាត់ទុកដំណើរទស្សនៈកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន ទៅទីក្រុង **Kitakyushu** កាលពីដើមខែកក្កដា កន្លងទៅនេះ ពិតជាបានពង្រឹងថែមទៀត នូវកិច្ចសហប្រតិបត្តិការកាន់តែ រឹងមាំឡើងរវាងកម្ពុជា និង ទីក្រុង **Kitakyushu** ដែលក្នុងនោះ ជាការកត់សំគាល់ គឺ **សម្តេចតេជោ** បានផ្តួចផ្តើមគំនិត ឱ្យមានសម្ព័ន្ធមេត្រីភាពរវាងទីក្រុងភ្នំពេញ និងទីក្រុង **Kitakyushu** ជប៉ុនផងដែរ ។

លោក **ISAYAMA Osamu** បានបន្ថែមថា:ការមកទស្សនៈកិច្ចនៅកម្ពុជា ក្រៅពីគោលបំណងដើម្បីបញ្ចប់គម្រោងទឹកស្អាតមួយនៅកម្ពុជា ក្រុមប្រតិភូរបស់លោក ដែលមានក្រុមហ៊ុនផ្សេងៗគ្នាជាច្រើន ក៏នឹងពិនិត្យលទ្ធភាពវិនិយោគលើប្រព័ន្ធ ទឹកស្អាត និងទឹកកខ្វក់ នៅតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មមួយចំនួននៅកម្ពុជាផងដែរ ។

ជាចុងក្រោយ ដៃគូសន្ទនាទាំងពីរបានសន្យា នឹងសហការគ្នាឱ្យបានកាន់តែរឹងមាំថែមទៀត ជាពិសេសដៃគូជប៉ុនត្រៀមជានិច្ច ក្នុងកិច្ចសហប្រតិបត្តិការភាពជាដៃគូ ក្នុងវិស័យអភិវឌ្ឍន៍ទឹកស្អាតនៅកម្ពុជា ។



